ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤១៥ ប្រក.កសក

# ប្រកាស
## ស្តីពី
## នីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia ១/៣៥ Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្មគ្រប់ប្រភេទ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅធានានូវគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃជីកសិកម្មគ្រប់ប្រភេទ ដោយអនុលោមតាមការតម្រូវបមាណីយនៅមុនពេលអនុញ្ញាតឲ្យធ្វើការនាំចូលនាំចេញ ធ្វើការលាយផ្សំ ឬធ្វើការវេចខ្ចប់ជាថ្មី សម្រាប់ការផ្គត់ផ្គង់ចែកចាយឬធ្វើចរាចរណ៍លើទីផ្សារ និងការប្រើប្រាស់គ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះជីកសិកម្មគ្រប់ប្រភេទ ដែលត្រូវបានប្រើប្រាស់ជាធាតុចូលក្នុងផលិតកម្មកសិកម្ម និងមានចំណាត់ថ្នាក់ដូចខាងក្រោម៖

១- ជីអសរីរាង្គឬជីគីមី។
២- ជីសរីរាង្គ។
៣- ជីជីវសាស្ត្រ។
៤- ជីកែលំអគុណភាពដី។
៥- ជីវត្ថុធាតុដើម។

អត្តសញ្ញាណនៃប្រភេទជីកសិកម្មនីមួយៗ ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី១នៃប្រកាសនេះ។

## ជំពូកទី ២
## ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម

**ប្រការ ៤.-**

អាចស្នើសុំការចុះបញ្ជីជីកសិកម្មក្នុងគោលបំណងធ្វើពាណិជ្ជកម្ម លុះត្រាតែនីតិបុគ្គលនោះបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សំណើសុំការចុះបញ្ជីជីកសិកម្មសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម ពុំតម្រូវឲ្យភ្ជាប់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឡើយ។

២/៣៥

ការិយាល័យតំណាងពាណិជ្ជកម្មឬទីភ្នាក់ងារពាណិជ្ជកម្ម សមាគម ឬអង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចស្នើសុំការចុះបញ្ជីជីកសិកម្មបានសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ប៉ុន្តែមិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មបានឡើយ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្មមានកាតព្វកិច្ចបំពេញការតម្រូវបមាណីយ ដោយត្រូវផ្ដល់ទិន្នន័យនិងព័ត៌មានពេញលេញ ពិតត្រឹមត្រូវ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់លើសេចក្ដីបញ្ជាក់អះអាងរបស់ខ្លួន។

**ប្រការ ៥.-**

ការតម្រូវទូទៅនូវព័ត៌មាននិងទិន្នន័យសម្រាប់ការចុះបញ្ជីជីកសិកម្មមានដូចខាងក្រោម៖

១ - ព័ត៌មានទូទៅ

១.១- នាមនិងអាសយដ្ឋានរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជី

១.២-ឈ្មោះនិងពាណិជ្ជសញ្ញានៃប្រភេទជីកសិកម្ម

១.៣-ឈ្មោះក្រុមហ៊ុននិងប្រទេសប្រភពដើមផលិតឬលាយផ្សំ និងផ្គត់ផ្គង់

១.៤- បមាណីយជានានៃសមាសធាតុឬសារធាតុចិញ្ចឹមដែលអះអាង ដោយភ្ជាប់នូវវិញ្ញាបនបត្របញ្ជាក់បមាណីយជានានៃជីកសិកម្ម ដែលចេញពីប្រទេសប្រភពដើមផលិតឬលាយផ្សំ ឬប្រទេសប្រភពដើមនាំចេញ

១.៥-លទ្ធផលវិភាគសមាសធាតុនៃជីកសិកម្មដែលចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១.៦-ប្រភេទ ទំហំសំបកវេចខ្ចប់

១.៧-ប្រភពនិងប្រភេទវត្ថុធាតុដើម

១.៨-សេចក្ដីសង្ខេបទូទៅអំពីដំណើរការផលិតកម្មឬការលាយផ្សំចេញពីប្រភពដើម។

២ - សំណាកនៃផលិតផល

២.១- សំណាកជីកសិកម្មយ៉ាងតិចចំនួន២សំណាក ដែលដកយកពីគំនរឬឡូត៍តែមួយចំពោះ៖

- ប្រភេទជីសរីរាង្គគោកមានបរិមាណយ៉ាងតិច៥០០ក្រាម ទៅ ១ ០០០ក្រាម
- ប្រភេទជីអសរីរាង្គគោកមានបរិមាណយ៉ាងតិច២៥០ក្រាម ទៅ១ ០០០ក្រាម
- ប្រភេទជីទឹកមានបរិមាណយ៉ាងតិច២៥០មិល្លីម៉ែត្រ ទៅ ១ ០០០មិល្លីម៉ែត្រ

៣/៣៥